**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

ភាគីដាក់ឯកសារ៖ មេធាវីការពារក្តីរបស់ មាស មុត

ដាក់ជូន៖ សហចៅក្រមស៊ើបអង្កេត

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ៦ ខែសីហា ឆ្នាំ២០១៨

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 24-Aug-2018, 11:34
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ (កោសលុប)**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សំណើរបស់ មាស មុត សុំអនុញ្ញាតដាក់សារណាបន្ថែមទៅលើចម្លើយរបស់ខ្លួនតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ**

---

**ដាក់ដោយ៖**

**សហមេធាវី៖**

អាង ឧត្តម

Michael G. KARNAVAS

**ផ្ញើជូន៖**

**សហចៅក្រមស៊ើបអង្កេត៖**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Michael BOHLANDER

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក មាស មុត តាមរយៈសហមេធាវីការពារក្តីរបស់គាត់ ("មេធាវីការពារក្តី") អនុលោមតាម មាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.[1] វិធាន ២១ និង ៣៩(៤) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. ("វិធាន") និង សិទ្ធិអំណាចឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតក្នុងការអនុវត្តច្បាប់ នៅពេលយល់ឃើញថាសមស្រប[2] តាមរយៈនេះ ស្នើសុំការអនុញ្ញាតឱ្យដាក់សារណាបន្ថែមទៅលើចម្លើយរបស់ខ្លួនតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ("ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ")[3]។ សំណើនេះត្រូវបានធ្វើឡើងជាចាំបាច់ ពីព្រោះកំហុសជាច្រើននៅក្នុងការវាយតម្លៃភស្តុតាង និង យុត្តាធិការបុគ្គល នៅក្នុងសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ("សេចក្តីពិចារណាលើដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១")[4] គឺជាព័ត៌មានដែលទើបរកឃើញថ្មីៗ ដែលត្រូវបានពោលប្រាស្រ័យ ប្រសិនបើមេធាវីការពារក្តីបានដឹងព័ត៌មានទាំងនេះ នៅពេលឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរនោះ។ ការទទួលយកសំណើនេះអាចធានាបាននូវសិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និង ទទួលបានដំណើរការនីតិវិធីត្រឹមត្រូវ ដោយប្រកាន់ភ្ជាប់នូវកាតព្វកិច្ចការពារក្តីដោយយកចិត្តទុករបស់មេធាវីការពារក្តី និងបញ្ចៀសភាពអយុត្តិធម៌ជាក់ស្តែង។ សហព្រះរាជអាជ្ញានឹងមិនទទួលរងផលប៉ះពាល់ឡើយ ហើយពេលវេលាចេញដីកាដំណោះស្រាយក្នុងរឿងក្តី ០០៣ របស់សហចៅក្រមស៊ើបអង្កេត ក៏មិនរងផលប៉ះពាល់នោះដែរ[5]។ ដោយសារភាពបន្ទាន់នៃសំណើនេះ មេធាវីការពារក្តីសុំដាក់សំណើនេះជាភាសាអង់គ្លេសជាមុនសិន ហើយការបកប្រែជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយ។

---

[1] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ ២០០៤) ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.")។

[2] បញ្ហានេះនឹងត្រូវពិភាក្សាបន្ថែមនៅក្នុងកថាខណ្ឌ ១៥ *ខាងក្រោម*។

[3] [redacted]

[4] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ("សេចក្តីពិចារណាលើដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១") ឯកសារ D308/3/1/20។

[5] *សូមមើល* ផែនការបញ្ចប់ អ.វ.ត.ក. (វិសោធនកម្មលើកទី ១៧) ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០១៨ កថាខណ្ឌ ១១ (iv)។

## I. សាវតារ

### ក. រឿងក្តី ០០៣

១. នៅថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០១៩ កិច្ចស៊ើបសួរតាមផ្លូវតុលាការក្នុងរឿងក្តី ០០៣ ត្រូវបានផ្តួចផ្តើមធ្វើឡើង ដោយផ្អែកលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ២ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៨ ទាក់ទងទៅនឹងកងទ័ពបដិវត្តន៍កម្ពុជា[6]។ នៅថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[7]។

២. នៅថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០១៥ លោក មាស មុត បានចូលបង្ហាញខ្លួននៅចំពោះមុខសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និង បានទទួលការជូនដំណឹងថា គាត់កំពុងត្រូវបានស៊ើបអង្កេតពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើបំពារបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និង ឧក្រិដ្ឋកម្មថ្នាក់ជាតិទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មចំនួន ១១ កន្លែង និង ព្រឹត្តិការណ៍នានា ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[8]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានលុបចោលបទចោទប្រកាន់មួយចំនួន ដែលបានធ្វើឡើងប្រឆាំងនឹងលោក មាស មុត *ដោយកំបាំងមុខ*[9] ហើយបានជូនដំណឹងថា នៅមុនបញ្ចប់កិច្ចស៊ើបសួរ គាត់អាចត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋបន្ថែមទៀត[10]។

---

6 [redacted]

7 [redacted]

8 [redacted]

9 [redacted]

10 [redacted]

៣. នៅថ្ងៃទី ១០ ខែមករា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានជូនដំណឹងដល់ភាគីអំពីការបិទកិច្ចស៊ើបសួរ[11] និង វិសាលភាពដែលបានកាត់បន្ថយ[12]។ នៅថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០១៧ បន្ទាប់ពីបានដោះស្រាយសំណើសុំកិច្ចស៊ើបសួរបន្ថែម សហចៅក្រមស៊ើបអង្កេតបានចេញសេចក្ដីជូនដំណឹងលើកទីពីរជូនដល់ភាគី[13]។

៤. នៅថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០១៨ សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានស្ថានពរដាច់ដោយឡែកពីគ្នា[14]។

៥. នៅថ្ងៃទី ១២ ខែមេសា ឆ្នាំ ២០១៨ មេធាវីការពារក្ដីបានដាក់ចម្លើយរបស់ខ្លួនតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ។

### ខ. រឿងក្ដី ០០៤/១

#### ១. សាវតារទាក់ទងនឹងសេចក្ដីពិចារណាលើដីកាដំណោះស្រាយក្នុងរឿងក្ដី ០០៤/១

៦. នៅថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ (សំអាងហេតុ) ដែលក្នុងនោះសហចៅក្រមស៊ើបអង្កេត បានផ្ដល់សំអាងហេតុពេញលេញចំពោះសេចក្ដីសម្រេចរបស់ខ្លួនដែលលើកលែងការចោទប្រកាន់ក្នុងរឿងក្ដី ០០៤/១ ដោយសារកង្វះយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. លើ អ៊ឹម ចែម[15]។

៧. នៅថ្ងៃទី ៩ ខែសីហា ឆ្នាំ ២០១៧ សហព្រះរាជអាជ្ញាអន្តរជាតិបានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ដោយចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេត៖ ក. មានកំហុសអង្គច្បាប់ក្នុង

---

11 [redacted]

12 [redacted]

13 [redacted]

14 [redacted]

15 *រឿងក្ដី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០១៧ (“ដីកាដំណោះស្រាយក្នុងរឿងក្ដី ០០៤/១”) ឯកសារ D261។

ការយល់ឃើញថា ការចោទប្រកាន់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវតែជាផ្នែកមួយនៃដីកាដំណោះស្រាយ[16] ខ. មានកំហុសអង្គច្បាប់ដោយខកខានមិនបានពោលប្រាស្រ័យពីការចោទប្រកាន់ដែលប្តឹងទៅសហចៅក្រមស៊ើបអង្កេត ប៉ុន្តែមិនបានដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ៖ (១) ការបោសសម្អាតនៅភូមិភាគពាយ័ព្យ (២) ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (៣) ការធ្វើទុក្ខបុកម្នេញលើប្រជាជនវៀតណាមក្នុងតំបន់ ៥ (៤) ការធ្វើទុក្ខបុកម្នេញលើខ្មែរក្រោមក្នុងតំបន់ ១៣ និង (៥) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយចំនួន នៅតាមទីតាំងជាក់លាក់[17] គ. មានកំហុសអង្គច្បាប់ និង អង្គហេតុ ក្នុងការអនុវត្តឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល[18] ឃ. មានកំហុសអង្គច្បាប់ និង អង្គហេតុ ក្នុងការអនុវត្តឧក្រិដ្ឋកម្មនៃការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ[19] ង. មានកំហុសអង្គហេតុក្នុងការយល់ឃើញថា អ៊ឹម ចែម មិនមែនជាលេខាស្រុកកោះអណ្តែត[20] និង ច. មានកំហុសអង្គហេតុក្នុងការយល់ឃើញថា អ៊ឹម ចែម មិនមែនជាសមាជិកគណៈតំបន់ ១៣[21]។

៨. នៅថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ អង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណាលើដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។ អង្គបុរេជំនុំជម្រះបានយល់ស្របគ្នាលើបញ្ហាមួយចំនួន[22] ប៉ុន្តែមិនអាចទទួលបានសំឡេងភាគច្រើន ដើម្បីគាំទ្រដល់អង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ[23]។ ចៅក្រមជាតិភាគច្រើនបានយល់ឃើញថា អ៊ឹម ចែម មិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ហើយក៏បានតម្កល់សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត[24]។ ចៅក្រម

[16] *រឿងក្តី អ៊ឹម ចែម* សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ជ.ប) បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ៩ ខែសីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1/1 កថាខណ្ឌ ១១-២២។

[17] *ដូចខាងលើ* កថាខណ្ឌ ២៣-៣៧។

[18] *ដូចខាងលើ* កថាខណ្ឌ ៣៨-៤៦។

[19] *ដូចខាងលើ* កថាខណ្ឌ ៤៧-៥៧។

[20] *ដូចខាងលើ* កថាខណ្ឌ ៥៨-៦៩។

[21] *ដូចខាងលើ* កថាខណ្ឌ ៧០-៨១។

[22] *សូមមើល* កថាខណ្ឌ ៩ *ខាងក្រោម* ។

[23] កថាខណ្ឌ ៨១ នៃសេចក្តីពិចារណាលើដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[24] *ដូចខាងលើ* យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ធុល និង ចៅក្រម ហួត វុទ្ធី កថាខណ្ឌ ៩២។

អន្តរជាតិភាគតិចបានពិនិត្យមើលសំណុំរឿង *ម្តងទៀត* (de novo) និង បានយល់ឃើញថា អ៊ឹម ចែម ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក.[25]។

### ២. សេចក្តីសម្រេចជាឯកច្ឆន្ទរបស់អង្គបុរេជំនុំជម្រះ

៩. អង្គជំនុំជម្រះបានសម្រេចថា៖ **ក.** រយៈពេលដែលសហចៅក្រមស៊ើបអង្កេតចំណាយសម្រាប់ចេញដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១ គឺ "មិនសមាមាត្រ"[26] **ខ.** ការចេញដីកាដំណោះស្រាយពីរដាច់ពីគ្នាមិនបានពន្លឿនឱ្យរឿងក្តី ០០៤/១ ឆាប់មានលទ្ធផល[27] **គ.** ការបំបែករឿងក្តីរបស់ អ៊ឹម ចែម ចេញពីរឿងក្តី ០០៤ បានធ្វើឱ្យប៉ះពាល់ដល់ការចោទប្រកាន់ដែលនៅសល់ក្នុងរឿងក្តី ០០៤[28] **ឃ.** គោលជំហររបស់ អ.វ.ត.ក. ក្នុងប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជា[29] មិនមានន័យថា តុលាការធម្មតាមិនមានយុត្តាធិការលើឧក្រិដ្ឋកម្មក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះទេ[30] **ង.** សហចៅក្រមស៊ើបអង្កេតបានបង្កើតមិនត្រឹមត្រូវនូវឋានានុក្រមនៃភស្តុតាង ក្នុងការពិចារណាលើតម្លៃជាភស្តុតាង[31] និង **ច.** សហចៅក្រមស៊ើបអង្កេតបានអនុវត្តបទដ្ឋាននៃភស្តុតាងមិនត្រឹមត្រូវ[32]។

### ៣. យោបល់ភាគតិចរបស់ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ

១០. ដោយផ្អែកលើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ក. បានច្រានចោលមូលដ្ឋាន ១ មូលដ្ឋាន ២(២) និង មូលដ្ឋាន ២(៤)[33] តម្កល់មូលដ្ឋាន ២(១) មូលដ្ឋាន ២(៣)

---

[25] *ដូចខាងលើ* យោបល់របស់ចៅក្រម Baik និង ចៅក្រម Beauvallet កថាខណ្ឌ ៣៣៩។

[26] *ដូចខាងលើ* កថាខណ្ឌ ២៨-៣១។

[27] *ដូចខាងលើ* កថាខណ្ឌ ៣២-៣៥។

[28] កថាខណ្ឌ ៣៦-៤០ នៃសេចក្តីពិចារណាលើដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[29] សហមេធាវីជាតិសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងពីបញ្ហានេះ ហើយអង្គបុរេជំនុំជម្រះបានស្នើសុំឱ្យមានការដាក់សារណា។ *ដូចខាងលើ* កថាខណ្ឌ ១៦-១៧ កថាខណ្ឌ ៦៤-៨០។

[30] *ដូចខាងលើ* កថាខណ្ឌ ៨០។

[31] *ដូចខាងលើ* កថាខណ្ឌ ៤១-៥៩។

[32] *ដូចខាងលើ* កថាខណ្ឌ ៦០-៦៣។ *សូមមើលផងដែរ ដូចខាងលើ* យោបល់របស់ចៅក្រម Baik និង ចៅក្រម Beauvallet កថាខណ្ឌ ១០៦-១២ (ទាក់ទងនឹងបទចោទប្រកាន់ និង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)។

[33] កថាខណ្ឌ ១១៨ កថាខណ្ឌ ១៤៦ កថាខណ្ឌ ១៦៨ នៃសេចក្តីពិចារណាលើដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

និង មូលដ្ឋាន ៣-៦[34] និង តម្កល់ផ្នែកខ្លះនៃមូលដ្ឋាន ២(៥) និង ច្រានចោលមូលដ្ឋានផ្សេងៗទៀត[35] **ខ.** បានពិនិត្យមើលសំណុំរឿង *ម្តងទៀត* និង បានពោលប្រាស្រ័យពីការចោទប្រកាន់ផ្នែកអង្គហេតុទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មទាំងប្រាំដែលមិនបានចោទប្រកាន់ ដែលមិនត្រូវបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ ដោយយល់ឃើញថា ការចោទប្រកាន់ទាំងនេះគួរតែត្រូវបានដាក់ឱ្យនៅក្រោមការត្រួតពិនិត្យ និង យកមកពិចារណាសម្រាប់គោលបំណងនៃយុត្តាធិការបុគ្គល[36] និង **គ.** បានសន្និដ្ឋានថា វិសាលភាពធំធេងនៃឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់ ឬ ដាក់ អ៊ឹម ចែម ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ព្រមទាំង តួនាទី និង ការទទួលខុសត្រូវរបស់គាត់ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ បានធ្វើឱ្យគាត់ស្ថិតនៅក្នុងចំណោមអ្នកដែល “ទទួលខុសត្រូវខ្ពស់បំផុត”[37]។

## II. ភាពទទួលយកបាននៃសំណើ

១១. នៅក្នុងសេចក្តីពិចារណាលើដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១ ដែលបានចេញនៅថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ បន្ទាប់ពីមេធាវីការពារក្តីបានដាក់ចម្លើយរបស់ខ្លួនតបទៅនឹងដីកាសន្និដ្ឋានស្ថាពរនោះ អង្គបុរេជំនុំជម្រះបានប្រព្រឹត្តកំហុសមួយចំនួន ដែលបើមិននិយាយអំពីកំហុសទាំងនេះទេ ធ្វើប៉ះពាល់ដល់សិទ្ធិរបស់លោក មាស មុត ក្នុងទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និង ទទួលបានដំណើរការនីតិវិធីត្រឹមត្រូវ និង បណ្តាលឱ្យមានភាពអយុត្តិធម៌ខ្លាំងក្លា។ ខណៈដែលសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះជារួម[38] មិនមានភាពសមហេតុ សមផល និង ជាពិសេសផលវិបាកនោះ[39] សំណើនេះគឺមានកម្រិតនៅត្រឹមកំហុសរបស់អង្គបុរេជំនុំជម្រះទាក់ទងនឹង៖

---

[34] *ដូចខាងលើ* កថាខណ្ឌ ១៤២ កថាខណ្ឌ ១៦០ កថាខណ្ឌ ២៦៣ កថាខណ្ឌ ២៨២ កថាខណ្ឌ ៣២០។

[35] *ដូចខាងលើ* កថាខណ្ឌ ១៧២ កថាខណ្ឌ ១៧៩ កថាខណ្ឌ ១៨៣ កថាខណ្ឌ ១៨៦ កថាខណ្ឌ ១៩៤ កថាខណ្ឌ ២០១ កថាខណ្ឌ ២០៦ កថាខណ្ឌ ២១១។

[36] *ដូចខាងលើ* កថាខណ្ឌ ២២៥ កថាខណ្ឌ ២៣២ កថាខណ្ឌ ២៤១ កថាខណ្ឌ ២៤៨។

[37] *ដូចខាងលើ* កថាខណ្ឌ ៣៣៩។

[38] *សូមមើល* កថាខណ្ឌ ៩-១០ *ខាងលើ* ។

[39] ទោះបីចៅក្រមអាចលើកពីកំហុសឆ្គង *ឯកឯង* (sua sponte) ក៏ដោយ ក៏អង្គបុរេជំនុំជម្រះ - មានសំឡេងដែលមានឥទ្ធិពលច្រើនលើសំណុំរឿងនេះ - បានសម្រេចលើបញ្ហាទាំងឡាយ ដែលមិនមែនជាកត្តាកំណត់ ឬ សំខាន់សម្រាប់បណ្តឹងឧទ្ធរណ៍។ ជាក់ស្តែង ចេតនារបស់អង្គបុរេជំនុំជម្រះ គឺនិយាយបង្អាក់សហចៅក្រមស៊ើបអង្កេត ប្រហែលជាដោយសារតែការមិនពេញចិត្តគុំគួនដែលនៅដិតដាមប្រឆាំងនឹងសហចៅក្រមស៊ើបអង្កេតក្នុងការស្នើសុំឱ្យដាក់សារណាថា តើវាអាចជាប្រយោជន៍យុត្តិធម៌ដែរឬយ៉ាងណា នៅពេលផ្អាកកិច្ចស៊ើបសួរជារៀងរហូត ដោយសារតែស្ថានភាពថវិកាមិនស្ថិតស្ថេររបស់ អ.វ.ត.ក. [redacted]

[redacted] ដោយគ្មានមូលហេតុ (និង មិនសមហេតុផល) អង្គបុរេជំនុំជម្រះ បានជំទាស់សំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងដីកាដំណោះស្រាយក្នុងរឿងក្ដី ០០៤/១ ដោយការលើកឡើងពីបញ្ហាមិនសំខាន់ចំនួនបួនដោយ *ឯកឯង* ដែលនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនពោរពេញទៅដោយកំហុស និង ការយល់ខុស។ **ទីមួយ** អង្គបុរេជំនុំជម្រះបានយល់ឃើញថា រយៈពេលដែលសហចៅក្រមស៊ើបអង្កេតចំណាយក្នុងការចេញដីកាដំណោះស្រាយក្នុងរឿងក្ដី ០០៤/១ គឺមិនសមាមាត្រ និង ថាការចេញដីកាដំណោះស្រាយពីរដាច់ពីគ្នាមិនបានពន្លឿនកិច្ចដំណើរការនីតិវិធី (កថាខណ្ឌ ២៨-៣៥ នៃសេចក្ដីពិចារណាលើដីកាដំណោះស្រាយក្នុងរឿងក្ដី ០០៤/១)។ បញ្ហានេះមិនមែនជាកត្តាកំណត់នៅក្នុងបណ្ដឹងឧទ្ធរណ៍ទេ។ អង្គបុរេជំនុំជម្រះខកខានមិនបានវិភាគឱ្យបានល្អិតល្អន់លើបញ្ហានេះ៖ **ក.** ខកខានមិនបានពិចារណាពីការកម្រិតធនធានថវិកា និង ធនធានមនុស្សដែលមាន (*សូមមើល ឧទា.* កថាខណ្ឌ ១៦-២៧ នៃផែនការបញ្ចប់ អ.វ.ត.ក. (វិសោធនកម្មលើកទី ៧) ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៥) **ខ.** មិនអើពើនឹងការណ៍ដែលសហចៅក្រមស៊ើបអង្កេតបានទទួលបណ្ដឹងរឿងក្ដីចំនួន ៤ ក្នុងពេលតែមួយ និង **គ.** វាយតម្លៃដោយភាន់ច្រឡំលើភាពស្មុគស្មាញនៃរឿងក្ដី ០០៤/១ ដោយផ្អែកលើចំនួនបទចោទ និយាយផ្ទុយទៅនឹងសេចក្ដីសម្រេចរបស់ខ្លួនឯងផ្ទាល់ដែលថា សហចៅក្រមស៊ើបអង្កេតត្រូវវាយតម្លៃភស្តុតាងទាំងអស់នៃឧក្រិដ្ឋកម្មដែលបានដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ និង ចោទប្រកាន់ មុននឹងចេញដីកាដំណោះស្រាយ (កថាខណ្ឌ ៣០ កថាខណ្ឌ ៣៧ នៃសេចក្ដីពិចារណាលើដីកាដំណោះស្រាយក្នុងរឿងក្ដី ០០៤/)។ ដីកាដំណោះស្រាយពីរដាច់ពីគ្នាគឺមានភាពសមហេតុផល៖ **១.** ផ្ដល់ឱ្យភាគីនូវការជូនដំណឹងពីលទ្ធផលនៃរឿងក្ដី និង **២.** ផ្ដល់នូវដីកាដំណោះស្រាយ *ដែលមានសំអាងហេតុ* ដូចដែលតម្រូវតាមវិធាន ៦៧(៤) នៃវិធានផ្ទៃក្នុង។ ការថ្កោលទោសរបស់អង្គបុរេជំនុំជម្រះចំពោះដីកាដំណោះស្រាយពីរខុសគ្នានេះ គឺមិនសមហេតុផលទេ។ អង្គបុរេជំនុំជម្រះខ្លួនឯង ធ្លាប់បានចេញសាលដីកាពីរដាច់ពីគ្នា ហើយអង្គជំនុំជម្រះតុលាការកំពូលក៏ធ្លាប់ធ្វើដូច្នេះដែរ។ *សូមមើល ឧទា. រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៧៥) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ ២០១១ ឯកសារ D427/1/26 និង *រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៧៥) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១១ ឯកសារ D427/1/30។ *សូមមើលផងដែរ រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សេចក្ដីសម្រេចលើសេចក្ដីជំទាស់ទៅនឹងបញ្ជីឯកសារសេចក្ដីសង្ខេប ចុះថ្ងៃទី ១ ខែកក្កដា ឆ្នាំ ២០១៥ ឯកសារ F26/11 និង *រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សេចក្ដីសម្រេចលើសេចក្ដីជំទាស់ទៅនឹងបញ្ជីឯកសារសំអាងហេតុពេញលេញ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ F26/12។ **ទីពីរ** អង្គបុរេជំនុំជម្រះបានពិចារណាថា វាជាការចាំបាច់ក្នុងការបញ្ជាក់បំភ្លឺផលប៉ះពាល់លើការបំបែករឿងក្ដី អ៊ឹម ចែម ចេញពីរឿងក្ដី ០០៤ (កថាខណ្ឌ ៣៦-៤០ នៃសេចក្ដីពិចារណាលើដីកាដំណោះស្រាយក្នុងរឿងក្ដី ០០៤/១)។ បញ្ហានេះមិនមែនជាកត្តាកំណត់នៅក្នុងបណ្ដឹងឧទ្ធរណ៍នោះទេ។ អង្គបុរេជំនុំជម្រះមិនបានរកឃើញកំហុស ឬ ការរំលោភបំពានណាមួយទៅលើឆន្ទានុសិទ្ធិដោយសហចៅក្រមស៊ើបអង្កេតឡើយ។ ដោយសារតែគ្មានការចេញដីកាដំណោះស្រាយក្នុងរឿងក្ដី ០០៤ និង រឿងក្ដី ០០៤/២ នោះ អង្គបុរេជំនុំជម្រះមិនចាំបាច់ចេញសេចក្ដីសម្រេចដែលមានសិទ្ធិបុព្វក្រយនោះទេ។ **ទីបី** អង្គបុរេជំនុំជម្រះបានយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានបំពេញកិច្ចហួសពីអាណត្តិរបស់ខ្លួន ក្នុងការសម្រេចថាច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. ដកហូតយុត្តាធិការរបស់តុលាការកម្ពុជាធម្មតាទៅលើរឿងក្ដីនៅសម័យខ្មែរក្រហម (*ដូចខាងលើ*

ក. វិធីសាស្ត្រក្នុងការវាយតម្លៃភស្តុតាងរបស់សហចៅក្រមស៊ើបអង្កេត[40] ខ. បទដ្ឋាននៃភស្តុតាងដើម្បីចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ[41] និង គ. ការវាយតម្លៃលើយុត្តាធិការបុគ្គល[42]។

១២. ប្រសិនបើបានដឹងកំហុសទាំងនេះ នៅមុនពេលដាក់ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរនោះ មេធាវីការពារក្តីនឹងលើកឡើងថា៖ ក. សហចៅក្រមស៊ើបអង្កេតបានអនុវត្តវិធីសាស្ត្រសមស្របក្នុងការវាយតម្លៃភស្តុតាងក្នុងសំណុំរឿង ០០៤/១ ខ. ចៅក្រមអង្គបុរេជំនុំជម្រះ និង សហចៅក្រមស៊ើបអង្កេតបានសំអាងមិនត្រឹមត្រូវលើដីកាដំណោះស្រាយក្នុងរឿងក្តី ០០២ ក្នុងការបង្កើតបទដ្ឋាននៃភស្តុតាង ដើម្បីចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលបទដ្ឋានត្រឹមត្រូវគឺថា *តើអង្គជំនុំជម្រះដែលមានហេតុផលមួយអាចផ្តន្ទាទោសជនត្រូវចោទឱ្យហួសពីវិមតិសង្ស័យ ដោយផ្អែកលើភស្តុតាងក្នុងសំណុំរឿងបានដែរឬយ៉ាងណា* និង គ. សហចៅក្រមស៊ើបអង្កេតគួរកំណត់យុត្តាធិការបុគ្គលដោយផ្អែកលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់តែប៉ុណ្ណោះ។

១៣. ដោយពិចារណាថា កំហុសទាំងនេះលេចឡើង បន្ទាប់ពីដាក់ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ ប៉ុន្តែមុនការចេញដីកាដំណោះស្រាយក្នុងរឿងក្តី ០០៣ កំហុសនេះគឺជាព័ត៌មានដែលទើបរកឃើញថ្មីៗ ដែលសមនឹងមានសារណាពីសំណាក់មេធាវីការពារក្តី អនុលោមទៅតាមកាតព្វកិច្ចបំពេញ

---

កថាខណ្ឌ ៦៤-៨០)។ មិនត្រឹមតែបញ្ហានេះមិនមែនជាកត្តាកំណត់នៅក្នុងបណ្តឹងឧទ្ធរណ៍ប៉ុណ្ណោះទេ ប៉ុន្តែ អង្គបុរេជំនុំជម្រះថែមទាំងបកស្រាយខុសទៅលើសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតទៀតផង។ សហចៅក្រមស៊ើបអង្កេតគ្រាន់តែបានពិចារណាពីផលប៉ះពាល់ជាសម្ភតិកម្មនៃការច្រានចោលរឿងក្តី ដែលផ្អែកតែទៅលើកង្វះយុត្តាធិការបុគ្គល និង ថាតើ "ចន្លោះនិទណ្ឌភាព" គួរត្រូវរងផលប៉ះពាល់ពីសេចក្តីសម្រេចរបស់ខ្លួនឬយ៉ាងណា ហើយនៅទីបំផុតបានធ្វើការសន្និដ្ឋានថា វាពុំរងផលប៉ះពាល់នោះទេ (កថាខណ្ឌ ១១-២៥ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១)។ ការយល់ឃើញរបស់អង្គបុរេជំនុំជម្រះ គឺច្រើនលើសពីតម្រូវការ។ អង្គបុរេជំនុំជម្រះមិនបានរកឃើញកំហុស ឬ ការរំលោភបំពានលើឆន្ទានុសិទ្ធិ និង ជាចុងក្រោយបានឯកភាពជាមួយនឹងសហចៅក្រមស៊ើបអង្កេតថា អ.វ.ត.ក. ត្រូវបានបង្កើតឡើង ដើម្បីកាត់ទោស "ចារីកម្រិតខ្ពស់ដែលមានចំនួនកំណត់" (កថាខណ្ឌ ៧៨ នៃសេចក្តីពិចារណាលើដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១)។ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានសន្និដ្ឋានដោយភាន់ច្រឡំបន្ថែមទៀតថា អលទ្ធភាពរបស់អង្គបុរេជំនុំជម្រះក្នុងការឈានទៅដល់ការឯកភាពគ្នាជាឯកច្ឆន្ទ ក្នុងរឿងក្តី ០០៤/១ មិនត្រូវរារាំងដល់ការជំនុំជម្រះក្តី នៅចំពោះមុខតុលាការជាតិទេ (*ដូចខាងលើ* កថាខណ្ឌ ៣៤០)។ មិនមានមូលដ្ឋានក្នុងការកំណត់ដូច្នេះឡើយ ពីព្រោះ "អ.វ.ត.ក. មិនមានយុត្តាធិការក្នុងការវិនិច្ឆ័យលើសកម្មភាពនៃស្ថាប័នដទៃទៀតឡើយ" (*ដូចខាងលើ* កថាខណ្ឌ ៧២ កថាខណ្ឌ ៧៩)។

[40] កថាខណ្ឌ ៤១-៥៩ នៃសេចក្តីពិចារណាលើដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[41] *ដូចខាងលើ* កថាខណ្ឌ ៦០-៦៣ កថាខណ្ឌ ១០៦-១២ (ទាក់ទងនឹងបទចោទប្រកាន់ និង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)។

[42] *ដូចខាងលើ* កថាខណ្ឌ ៣២១-២២។

ភារកិច្ចដោយការយកចិត្តទុកដាក់របស់ខ្លួន[43]។ ការវិវឌ្ឍន៍ថ្មីៗនេះធ្វើឱ្យមានព័ត៌មានថ្មី ដែលមានតម្លៃស្មើនឹងភស្តុតាងដែលទើបរកឃើញថ្មី ស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ ភស្តុតាងនេះអាចទទួលយកបាន និង ត្រូវបានពិចារណា ប្រសិនបើវាអាចជួយដល់ការស្វែងរកការពិត និង មិនមាននៅមុនពេលចាប់ផ្តើមការជំនុំជម្រះ ឬ មិនអាចរកឃើញ បន្ទាប់ពីបានបំពេញកិច្ចដោយយកចិត្តទុកដាក់ត្រឹមត្រូវហើយនោះ[44]។

១៤. កំហុសទាក់ទងនឹងការវាយតម្លៃភស្តុតាង និង យុត្តាធិការបុគ្គល អាចមានផលប៉ះពាល់ធ្ងន់ធ្ងរលើដីកាដំណោះស្រាយរបស់លោក មាស មុត។ ការទទួលយកសំណើនេះនឹងស៊ីចង្វាក់ជាមួយនឹងច្បាប់ដែលគ្រប់គ្រង អ.វ.ត.ក. ដែលតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតធានាឱ្យមានកិច្ចដំណើរការនីតិវិធីត្រឹមត្រូវ និង ការពារសិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ អនុលោមតាមមាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ចៅក្រមនៅ អ.វ.ត.ក. ទាំងអស់ ត្រូវអនុវត្តសមត្ថកិច្ចរបស់ខ្លួនស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និង ដំណើរការសមស្របនៃច្បាប់ ដូចមានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[45] ដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញកម្ពុជា[46]។ វិធាន ២១ នៃវិធានផ្ទៃក្នុង តម្រូវឱ្យ

---

[43] វិធាន ALASKA ស្តីពីក្រមសីលធម៌វិជ្ជាជីវៈ (ឆ្នាំ ២០១៧-ឆ្នាំ ២០១៨) វិធាន ១.៣។ *ដូចខាងលើ* មតិយោបល់លើវិធាន ១.៣៖ “មេធាវីការពារក្តីត្រូវការពាររឿងក្តីឱ្យកូនក្តី បើទោះបីខ្លួនមានការយល់ឃើញផ្ទុយ មានឧបសគ្គ ឬ មានភាពលំបាកផ្ទាល់ខ្លួនក៏ដោយ ហើយត្រូវចាត់វិធានការតាមផ្លូវច្បាប់ និង ក្រមសីលធម៌ដែលចាំបាច់ ដើម្បីបង្ហាញភស្តុតាងគាំទ្របុព្វហេតុ ឬ កិច្ចខិតខំប្រែងរបស់កូនក្តីខ្លួន។ មេធាវីការពារក្តីក៏ត្រូវបំពេញកិច្ចដោយប្តេជ្ញា និង ការលះបង់ ដើម្បីជាប្រយោជន៍ដល់កូនក្តី និង តតាំងក្តីជំនួសឱ្យកូនក្តីរបស់ខ្លួន”។ *សូមមើលផងដែរ* មាត្រា ៧ នៃក្រមសីលធម៌មេធាវី ដែលទទួលបានការអនុញ្ញាតពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ មាត្រា ៥៨ នៃច្បាប់ស្តីពីលក្ខន្តិកៈគណៈមេធាវី (ឆ្នាំ ១៩៩៥)។ វិធាន ២២(៤) នៃវិធានផ្ទៃក្នុង។

[44] វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និង បញ្ហាពាក់ព័ន្ធដទៃទៀត ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០១២ ឯកសារ E190 កថាខណ្ឌ ២២-២៣។ *សូមមើលផងដែរ* វិធាន ១១២(១)(ក) នៃវិធានផ្ទៃក្នុង ទាក់ទងនឹងបណ្តឹងសើរើចំពោះសាលក្រមស្ថាពរ នៅពេលដែលភស្តុតាងថ្មីត្រូវបានរកឃើញ។

[45] មាត្រា ១៤-១៥ នៃកតិសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ដែលបានអនុម័ត និង បើកឱ្យចុះហត្ថលេខា ផ្តល់សច្ចាប័ន និង ចូលជាសមាជិក តាមសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាតិលេខ ២២០០ A (XXI) ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៦៦ ដែលចូលជាធរមាននៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៩៧៦ ស្របតាមមាត្រា ៤៩។ *សូមមើលផងដែរ* មាត្រា ៣៥ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ មាត្រា ១២-១៣ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាល

សហចៅក្រមស៊ើបអង្កេតបកស្រាយច្បាប់ អ.វ.ត.ក. និង វិធានផ្ទៃក្នុង ជាធរមាន ដើម្បីការពារជានិច្ចដល់ប្រយោជន៍របស់លោក មាស មុត[47]។ វិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង អនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតផ្ដល់សុពលភាពចំពោះកិច្ចទាំងឡាយណា ដែលធ្វើដោយភាគី បន្ទាប់ពីហួសពេលវេលាកំណត់។ ក្របខណ្ឌច្បាប់នេះ គាំទ្រដល់ការទទួលយកសំណើនេះ ដើម្បីការពារសិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ និង ដំណើរការនីតិវិធីត្រឹមត្រូវ។

## III. សំណើ

១៥. ទោះបីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា ការអនុវត្តនីត្យានុកូលភាព និង ការបកស្រាយរបស់អង្គបុរេជំនុំជម្រះ អាចជំរុញឱ្យមានសច្ចភាពផ្លូវច្បាប់ និង សេដ្ឋកិច្ចតុលាការក្ដី[48] ក៏ *ទ្រឹស្ដីយុត្តិសាស្ត្រ* (stare decisis) មិនអាចយកមកអនុវត្តបានឡើយ ក្នុងប្រព័ន្ធច្បាប់ស៊ីវិល

កម្ពុជាទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ ២០០៣) ("កិច្ចព្រមព្រៀង")។

[46] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ដែលបានកែប្រែដោយព្រះរាជក្រម ចុះថ្ងៃទី ៨ ខែមីនា ឆ្នាំ ១៩៩៩ ប្រកាសឱ្យប្រើវិសោធនកម្មមាត្រា ១១, ១២, ១៣, ១៨, ២២, ២៤, ២៦, ២៨, ៣០, ៣៤, ៥១, ៩០, ៩១, ៩៣ និង មាត្រាផ្សេងៗទៀតពីជំពូក ៨ ទៅ ជំពូក ១៤ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ៤ ខែមីនា ឆ្នាំ ១៩៩៩។

[47] វិធាន ២១(១) នៃវិធានផ្ទៃក្នុង។ [redacted] ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និង សំណុំរឿង ០០៤/២ និង សារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្ដី យឹម ទិត្យ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៧ ឯកសារ D249/6 កថាខណ្ឌ ១៨។ *រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ៧១) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្ដីសម្រេចរបស់ ក.ស.ច.ស. បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់ លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា អនុលោមតាមវិធានផ្ទៃក្នុង ៦៦ និង សេចក្ដីសង្កេតបន្ថែម និង សំណើសុំផ្អាកដំណើរការនីតិវិធី ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D390/1/2/4 កថាខណ្ឌ ១៣ កថាខណ្ឌ ២៣។

[48] ដីកាសម្រេចលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង ចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ ចុះថ្ងៃទី ៥ ខែមេសា ឆ្នាំ ២០១៦ ឯកសារ D87/2/1.7/1 កថាខណ្ឌ ១៣-១៥។

ដែល "ចៅក្រមមានកាតព្វកិច្ចត្រូវគោរពតាមច្បាប់តែប៉ុណ្ណោះ"[49]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានយល់ឃើញបន្ថែមទៀតថា "គោលការណ៍នីត្យានុកូលភាព ដែលបង្កើតឡើងដោយអង្គបុរេជំនុំជម្រះ ជាវិធានពុំបានចងកាតព្វកិច្ចឱ្យសហចៅក្រមស៊ើបអង្កេត គោរពតាមនៅក្នុងការបកស្រាយច្បាប់នោះទេ"[50]។ ប្រសិនបើសំណើនេះត្រូវបានអនុញ្ញាត មេធាវីការពារក្តីស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតងាកចេញពីគោលការណ៍នីត្យានុកូលភាព និង ការបកស្រាយ ដែលអង្គបុរេជំនុំជម្រះបានលើកឡើងនៅក្នុងសេចក្តីពិចារណាលើដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

**ក. អង្គបុរេជំនុំជម្រះបានយល់ឃើញដោយភាន់ច្រឡំថា សហចៅក្រមស៊ើបអង្កេតបានវាយតម្លៃមិនត្រឹមត្រូវលើភស្តុតាងនៅក្នុងរឿងក្តី ០០៤/១**

**១. សហចៅក្រមស៊ើបអង្កេតបានវាយតម្លៃភស្តុតាងទៅតាមមូលដ្ឋាននៃករណីនីមួយៗ**

១៦. អង្គបុរេជំនុំជម្រះបានយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមានកំហុសក្នុង៖ **ក.** ការវាយតម្លៃលើភស្តុតាងក្នុងរឿងក្តី ០០៤/១ ពីព្រោះគោលការណ៍សេរីភាពភស្តុតាង មានន័យថាភស្តុតាងទាំងអស់គឺអាចទទួលយកបាន និង ជាទូទៅមានតម្លៃជាភស្តុតាងស្មើគ្នា[51] **ខ.** ការបង្កើតឋានានុក្រមនៃភស្តុតាងក្នុងសំណុំរឿង ផ្អែកលើប្រភពដើមជាជាងខ្លឹមសារ[52] **គ.** ការផ្តល់តម្លៃជាភស្តុតាងខ្ពស់ចំពោះភស្តុតាងដែលទទួលបានពីការិយាល័យរបស់ខ្លួនជាជាងភស្តុតាងផ្សេងទៀត[53] និង **ឃ.** ការថ្លែងពីវិធីសាស្ត្រដែលពួកគេបានយកមកប្រើ ដើម្បីវាយតម្លៃភស្តុតាង[54]។

១៧. ប្រសិនបើសំណើសុំនេះត្រូវបានអនុញ្ញាត មេធាវីការពារក្តីស្នើសុំឱ្យពិចារណាថា៖

---

[49] *ដូចខាងលើ* កថាខណ្ឌ ១៣។

[50] *ដូចខាងលើ*។

[51] កថាខណ្ឌ ៤៤ នៃសេចក្តីពិចារណាលើដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។ *សូមមើល ដូចខាងលើ* កថាខណ្ឌ ៤១-៥៩ សម្រាប់សេចក្តីសម្រេចទាំងអស់។

[52] *ដូចខាងលើ* កថាខណ្ឌ ៥២។

[53] *ដូចខាងលើ* កថាខណ្ឌ ៤៩។

[54] *ដូចខាងលើ* កថាខណ្ឌ ៤១-៤២។

ក. អង្គបុរេជំនុំជម្រះ បានបកស្រាយខុសអំពីកិច្ចរបស់សហចៅក្រមស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតជាដំបូងបានវាយតម្លៃភស្តុតាងទាំងអស់នៅក្នុងសំណុំរឿង និង បន្ទាប់មកបានថ្លែងពីវិធីសាស្ត្ររបស់ខ្លួនក្នុងការធ្វើដូច្នេះ។ ពួកគេមិនបានបង្កើតឋានានុក្រម ឬ ដកចេញនូវប្រភេទនៃភស្តុតាងដោយផ្អែកលើប្រភពដើមនោះទេ។ ពួកគេបានវាយតម្លៃដោយសេរីលើតម្លៃជាភស្តុតាងតាមមូលដ្ឋាននៃករណីនីមួយៗ[55] ហើយបានពិចារណាដោយសមហេតុផលលើយុត្តិសាស្ត្ររបស់ អ.វ.ត.ក. ដែលមានយ៉ាងច្បាស់លាស់ ទាក់ទងនឹងប្រភេទផ្សេងៗនៃភស្តុតាង[56]។

ខ. សហចៅក្រមស៊ើបអង្កេត អាចវាយតម្លៃភស្តុតាងតាមលំដាប់ណាមួយ ដែលពួកគេជ្រើសរើស និង វាយតម្លៃលើតម្លៃជាភស្តុតាងតាមតែពួកគេមើលឃើញថាសមស្រប ដូចដែលពួកគេបានធ្វើនៅក្នុងរឿងក្តី ០០៤/១៖

- **កំណត់ហេតុនៃការស្តាប់ចម្លើយ៖** សហចៅក្រមស៊ើបអង្កេត បានវាយតម្លៃថា តើចម្លើយមានមូលដ្ឋានគាំទ្រ[57] ស៊ីចង្វាក់គ្នា[58] និង គួរឱ្យជឿជាក់[59] បានដែរឬយ៉ាងណា និង ថា តើសាក្សីមានការដឹងផ្ទាល់ដែលគួរឱ្យជឿជាក់បាន[60] ឬ មូលហេតុលាក់កំបាំង[61] ដែរឬយ៉ាងណា។

---

[55] *ដូចខាងលើ* កថាខណ្ឌ ៥១។ *សូមមើល* វិធាន ៥៥(៥) វិធាន ៦៧ នៃវិធានផ្ទៃក្នុង។ មាត្រា ១២៧ មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ ២០០៧)។ មាត្រា ៨១ មាត្រា ១៧៦-៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង (ឆ្នាំ ២០១៨)។ *សូមមើលផងដែរ* CHRISTIAN GUÉRY លិបិក្រមនៃនីតិព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌ ការស៊ើបអង្កេតបឋម (RÉPERTOIRE DE DROIT PÉNAL ET DE PROCÉDURE PÉNALE, INSTRUCTION PRÉPARATOIRE) (Dalloz ខែមិថុនា ឆ្នាំ ២០១៣) កថាខណ្ឌ ៧៩៩៖ “Le juge d'instruction … décide en toute indépendance sur le règlement de l'information.” (ការបកប្រែមិនផ្លូវការ៖ “ចៅក្រមស៊ើបអង្កេត… ត្រូវសម្រេចដោយឯករាជ្យ ដោយផ្អែកទៅលើលទ្ធផលនៃដំណើរការនីតិវិធី”)។

[56] ជើងទំព័រ ១៧៩-៨៩, ២៤៩-៥០ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[57] *សូមមើល ឧទា. ដូចខាងលើ* កថាខណ្ឌ ១៤៣-៥០ កថាខណ្ឌ ១៥៨ កថាខណ្ឌ ១៩០-៩១ កថាខណ្ឌ ២៤៨-៥១ កថាខណ្ឌ ២៧៦។

[58] *សូមមើល ឧទា. ដូចខាងលើ* កថាខណ្ឌ ១៦៥ កថាខណ្ឌ ២១១-១២។

[59] *សូមមើល ឧទា. ដូចខាងលើ* កថាខណ្ឌ ១៩៣-៩៤ កថាខណ្ឌ ២១៣-១៥ កថាខណ្ឌ ២៧៩-៨០។

[60] *សូមមើល ឧទា. ដូចខាងលើ* កថាខណ្ឌ ១៧៦។

[61] *សូមមើល ឧទា.* កថាខណ្ឌ ២០៣ កថាខណ្ឌ ២១០-១២ កថាខណ្ឌ ២៣២ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

- **ចម្លើយដែល អ៊ឹម ចែម ផ្តល់ឱ្យស្ថាប័នមិនមែន អ.វ.ត.ក.៖** សហចៅក្រមស៊ើបអង្កេតបានវាយតម្លៃចម្លើយទាំងនេះដោយផ្អែកលើភស្តុតាងផ្សេងទៀត[62] និង បានបញ្ជាក់ថា តើចម្លើយទាំងនេះមានមូលដ្ឋានគាំទ្រដែរឬយ៉ាងណា[63]។

- **ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី៖** សហចៅក្រមស៊ើបអង្កេតបានសំអាងលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលបានពីការិយាល័យរបស់ខ្លួន[64]។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានដាក់ ដើម្បីជួយដល់ការកាត់ទោស[65] ហើយសមនឹងទទួលបានការពិចារណាដោយប្រុងប្រយ័ត្ន ដោយសារភារកិច្ចរបស់សហចៅក្រមស៊ើបអង្កេតត្រូវស៊ើបអង្កេតដោយមិនលំអៀង[66]។

- **របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា៖** សហចៅក្រមស៊ើបអង្កេតបានវាយតម្លៃរបាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា លើខ្លឹមសារ ភាពគួរឱ្យជឿជាក់បាន និង ភាពមិនស្របគ្នា[67]។ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា របាយការណ៍ទាំងនោះមានតម្លៃជាភស្តុតាងតិចតួច[68] ដូចដែលចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានសន្និដ្ឋានដែរ[69]។

- **ការប៉ាន់ប្រមាណចំនួនជនរងគ្រោះ៖** សហចៅក្រមស៊ើបអង្កេតបានសំអាងលើគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* (in dubio pro reo) ដើម្បីប៉ាន់ស្មានចំនួន

---

[62] *ដូចខាងលើ* កថាខណ្ឌ ១៣៩។

[63] *សូមមើល ឧទា. ដូចខាងលើ* កថាខណ្ឌ ១៥៥ កថាខណ្ឌ ២២២-២៣។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ១៤៥-៤៩។

[64] *សូមមើល ឧទា. ដូចខាងលើ* កថាខណ្ឌ ២១៥ កថាខណ្ឌ ២៣០ កថាខណ្ឌ ២៧៧។

[65] វិធាន ២៣(១)(ក) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះបានសម្រេចដោយភាន់ច្រឡំថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានដាក់ក្នុងគោលបំណងដើម្បីជួយដល់ការស៊ើបអង្កេតតុលាការ។ កថាខណ្ឌ ៥៤ នៃសេចក្តីពិចារណាលើដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[66] វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង។

[67] កថាខណ្ឌ ១១៣-៣៥ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[68] *ដូចខាងលើ* កថាខណ្ឌ ១៣៥។

[69] កថាខណ្ឌ ២២៨ កថាខណ្ឌ ២៣៩ នៃសេចក្តីពិចារណាលើដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១ (ដែលវាយតម្លៃអំពីរបាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ ១៩៩៧)។

ជនរងគ្រោះ[70] ដែលជាវិធីសាស្ត្រត្រឹមត្រូវ នៅពេលមានការសង្ស័យទាក់ទងនឹងភស្តុតាង[71]។ ផ្ទុយទៅវិញ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានសំអាងលើភស្តុតាងប្រយោលយ៉ាងខ្លាំង ដើម្បីកំណត់ចំនួនជនរងគ្រោះនៅការដ្ឋាន[72]។

**២. សហចៅក្រមស៊ើបអង្កេត មិនបានប្រើបទដ្ឋាននៃភស្តុតាងលើសពីវិមតិសង្ស័យ ដើម្បីចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ**

១៨. អង្គបុរេជំនុំជម្រះ៖ **ក.** បានយល់ឃើញថា ការសំអាងរបស់សហចៅក្រមស៊ើបអង្កេតលើយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង និង អង្គជំនុំជម្រះតុលាការកំពូល បានបង្ហាញថា ពួកគេបានប្រើប្រាស់បទដ្ឋាននៃភស្តុតាងលើសពីវិមតិសង្ស័យ ជាជាងបទដ្ឋានភវនីយភាព[73] និង **ខ.** បានសម្រេចថា បទដ្ឋាននៃភស្តុតាងដែលអាចអនុវត្តបាន ដើម្បីចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺជាបទដ្ឋានភវនីយភាព[74]។

១៩. ប្រសិនបើសំណើនេះត្រូវបានអនុញ្ញាត មេធាវីការពារក្តីស្នើសុំឱ្យពិចារណាថា៖

ក. អង្គបុរេជំនុំជម្រះ បានបកស្រាយខុសអំពីការសំអាងរបស់សហចៅក្រមស៊ើបអង្កេតលើយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង និង អង្គជំនុំជម្រះតុលាការកំពូល។ សហចៅក្រមស៊ើបអង្កេតបានថ្លែងយ៉ាងច្បាស់លាស់ថា ការយល់ឃើញអំពីអង្គហេតុរបស់ពួកគេ គឺសំអាងលើបទដ្ឋានភវនីយភាព[75]។ សហចៅក្រមស៊ើបអង្កេតមិនបានប្រើប្រាស់យុត្តិសាស្ត្ររបស់អង្គ

---

[70] *សូមមើល ឧទា.* កថាខណ្ឌ ២១៨ កថាខណ្ឌ ២៨២ កថាខណ្ឌ ៣២០ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ២៦-៣៦។

[71] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក (០៤) សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៣១។

[72] កថាខណ្ឌ ២១៩-២០ នៃសេចក្តីពិចារណាលើដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[73] *ដូចខាងលើ* កថាខណ្ឌ ៦០។

[74] *ដូចខាងលើ* កថាខណ្ឌ ៦១។ *សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ១០៦-១២ (ទាក់ទងនឹងភាពខុសគ្នារវាងបទចោទប្រកាន់ និង ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)។

[75] កថាខណ្ឌ ២ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

ជំនុំជម្រះ ដើម្បីអនុវត្តបទដ្ឋាននៃភស្តុតាងផ្សេងទៀតឡើយ គ្រាន់តែដើម្បីគាំទ្រការវាយតម្លៃភស្តុតាងរបស់ខ្លួនប៉ុណ្ណោះ។

ខ. អង្គបុរេជំនុំជម្រះ និង សហចៅក្រមស៊ើបអង្កេត បានសំអាងមិនត្រឹមត្រូវលើបទដ្ឋានភវនីយភាព[76]។ ដោយសារតែឧក្រិដ្ឋកម្មត្រូវបានកាត់ទោសនៅ អ.វ.ត.ក. បទដ្ឋាននៃភស្តុតាងសម្រាប់ចោទប្រកាន់ជនសង្ស័យ រយៈពេលនៃកិច្ចស៊ើបសួរ និង លទ្ធភាពនៃការផ្តល់ថវិកាមិនគ្រប់គ្រាន់សម្រាប់រឿងក្តី ០០៣ បទដ្ឋាននៃភស្តុតាងដ៏ត្រឹមត្រូវ គឺ *ថាតើអង្គជំនុំជម្រះសាលាដំបូងសមហេតុផលមួយអាចផ្តន្ទាទោសជនត្រូវចោទ ឱ្យលើសពីវិមតិសង្ស័យ ដោយផ្អែកលើភស្តុតាងនៅក្នុងសំណុំរឿងបានដែរឬយ៉ាងណា*[77]។

**ខ. ការវាយតម្លៃលើយុត្តាធិការបុគ្គលរបស់សហចៅក្រមស៊ើបអង្កេត**

២០. ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានដកស្រង់សាលក្រមក្នុងរឿងក្តី ០០១ ដែលបានសម្រេចថា ដើម្បីកំណត់ថាតើនរណាម្នាក់ "ជាអ្នកទទួលខុសត្រូវខ្ពស់បំផុត" ភាពធ្ងន់ធ្ងរនៃ "ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ឬ ត្រូវចោទ" ត្រូវតែបានវាយតម្លៃ[78]។

២១. ប្រសិនបើសំណើនេះត្រូវបានអនុញ្ញាត មេធាវីការពារក្តីស្នើសុំឱ្យពិចារណាថា៖

ក. ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានថ្លែងខុសអំពីសាលក្រមក្នុងរឿងក្តី ០០១[79] និង បានដកស្រង់យុត្តិសាស្ត្រអន្តរជាតិមិនចំ[80]។ បើទោះបីជាមានការថ្លែងខុសអំពីយុត្តិសាស្ត្ររបស់អង្គ

---

[76] *ដូចខាងលើ* កថាខណ្ឌ ២ ជើងទំព័រ ២។ កថាខណ្ឌ ៦១ នៃសេចក្តីពិចារណាលើដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១ ដែលដកស្រង់ពី *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D427 ("ដីកាដំណោះស្រាយក្នុងរឿងក្តី ០០២") កថាខណ្ឌ ១៣២៣។ រឿងក្តី ០០២ សហចៅក្រមស៊ើបអង្កេតបានដកស្រង់មិនចំអំពីយុត្តិសាស្ត្រ និង មតិយោបល់របស់បារាំង និង អន្តរជាតិ។ *សូមមើល* កថាខណ្ឌ ១៣២៣-២៥ នៃដីកាដំណោះស្រាយក្នុងរឿងក្តី ០០២។ អង្គបុរេជំនុំជម្រះបានដកស្រង់វិធានផ្ទៃក្នុង ៥៥(៤) នៃវិធានផ្ទៃក្នុង និង មតិយោបល់របស់បារាំង ដែលមិនអាចអនុវត្តបាន។ *សូមមើល* កថាខណ្ឌ ៦២ នៃសេចក្តីពិចារណាលើដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[77] [redacted]

[78] កថាខណ្ឌ ៣២១ នៃសេចក្តីពិចារណាលើដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

ជំនុំជម្រះក្នុងរឿងក្តី ០០១ ក៏ដោយ ក៏ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានអនុវត្តយុត្តិសាស្ត្រនេះត្រឹមត្រូវក្នុងករណីមួយចំនួនផងដែរ[81]។

ខ. សហចៅក្រមស៊ើបអង្កេត គួរតែអនុវត្តតាមយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះក្នុងរឿងក្តី ០០១ និង ពិចារណាតែទៅលើឧក្រិដ្ឋកម្មដែលបានដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ក្នុងការវាយតម្លៃលើយុត្តាធិការបុគ្គល[82]។ កិច្ចព្រមព្រៀង[83] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.[84] និង វិធានផ្ទៃ

---

[79] *រឿងក្តី កាំង ហ្កេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ សាលក្រម ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១០ ("សាលក្រមក្នុងរឿងក្តី ០០១") ឯកសារ E188 កថាខណ្ឌ ២២ ដែលយោងការវាយតម្លៃលើ "ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់"។

[80] ជើងទំព័រ ៩០៦ នៃសេចក្តីពិចារណាលើដីកាដំណោះស្រាយក្នុងរឿង ០០៤/១ ដែលដកស្រង់ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Norman និង អ្នកផ្សេងទៀត* សំណុំរឿងលេខ SCSL-២០០៤-១៤-PT សេចក្តីសម្រេចលើញត្តិបឋមរបស់មេធាវីការពារក្តីស្តីពីកង្វះយុត្តាធិការបុគ្គលតំណាងឱ្យជនជាប់ចោទ Fofana ចុះថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០០៤ កថាខណ្ឌ ៣៨ (ការពិនិត្យលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ស្របតាមបទដ្ឋាននៃការបញ្ជាក់បទចោទប្រកាន់ "មូលដ្ឋានសមហេតុផលគួរឱ្យជឿជាក់បាន" របស់តុលាការ SCSL។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Ntaganda* សំណុំរឿងលេខ ICC-01/04-169-US-Exp សាលដីកាលើបណ្តឹងសាទុក្ខរបស់ព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ I ចំណងជើងថា "សេចក្តីសម្រេចលើពាក្យសុំរបស់ព្រះរាជអាជ្ញាឱ្យមានដីកាចាប់ខ្លួន មាត្រា ៥៨" ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៦ កថាខណ្ឌ ៧៦ (*សូមមើល ដូចខាងលើ* កថាខណ្ឌ ៧៨-៧៩ ដែលពិភាក្សាពីដែនកំណត់នៃលក្ខន្តិកៈទីក្រុងរ៉ូមលើយុត្តាធិការបុគ្គល)។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Lukić & Lukić* សំណុំរឿងលេខ IT-៩៨-៣២/១-PT សេចក្តីសម្រេចលើការបញ្ជូនសំណុំរឿង អនុលោមតាមវិធាន ១១ *ស្ទួន* ដោយភ្ជាប់នូវឧបសម្ព័ន្ធសម្ងាត់ ក និង ខ ចុះថ្ងៃទី ៥ ខែមេសា ឆ្នាំ ២០០៧ កថាខណ្ឌ ២៦ (*សូមមើលផងដែរ ដូចខាងលើ* កថាខណ្ឌ ៣ ទាក់ទងនឹងពេលដែលបញ្ជូនជនដែលត្រូវបញ្ជូនទៅជំនុំជម្រះឱ្យអាជ្ញាធររបស់រដ្ឋ ដើម្បីកាត់ទោស តាមវិធាន ១១ *ស្ទួន* នៃវិធានរបស់សាលាក្តី ICTY)។ [redacted]

[81] *សូមមើល* កថាខណ្ឌ ១៦៥-៦៨ កថាខណ្ឌ ២០៥-០៦ នៃសេចក្តីពិចារណាលើដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/១។

[82] កថាខណ្ឌ ២២ នៃសាលក្រមក្នុងរឿងក្តី ០០១។

[83] មាត្រា ១ នៃកិច្ចព្រមព្រៀង៖ "គោលបំណងរបស់កិច្ចព្រមព្រៀងនេះ គឺកំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា **ដើម្បីកាត់សេចក្តី**មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ..."។ ៥(៣)៖ "វិសាលភាពនៃការស៊ើបអង្កេត គឺកំណត់ត្រឹមតែមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និង ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ... ដែលបាន**ប្រព្រឹត្ត**ក្នុងអំឡុង... (ការគូសបញ្ជាក់បន្ថែម)។

[84] មាត្រា ១ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ៖ "ច្បាប់នេះរៀបចំឡើងក្នុងគោលបំណង**វិនិច្ឆ័យទោស** មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និង ការរំលោភបំពាន់យ៉ាងធ្ងន់ធ្ងរទៅលើ ... ដែល

ក្នុង[85] គាំទ្រជំហរនេះ។ ការប្រើប្រាស់ឧក្រិដ្ឋកម្មដែលមានមិនគ្រប់គ្រាន់[86] ដើម្បីវាយតម្លៃយុត្តាធិការបុគ្គល បញ្ជូនរឿងក្តីទៅជំនុំជម្រះ មានន័យថា ជនត្រូវចោទត្រូវបានកាត់ទោសមួយផ្នែក ដោយផ្អែកលើការចោទប្រកាន់ ដែលគាត់មិនអាចតវ៉ាជំទាស់បាននៅពេលជំនុំជម្រះក្នុងសវនាការ ដែលរំលោភលើសិទ្ធិរបស់គាត់ ក្នុងការទទួលបានការជូនដំណឹងអំពីបទចោទប្រកាន់ និង រៀបចំការពារក្តី[87]។

## IV. សេចក្តីសន្និដ្ឋាន

២២. ចៅក្រមនៃអង្គបុរេជំនុំជម្រះ មានកំហុសទាក់ទងនឹងការវាយតម្លៃលើភស្តុតាងរបស់សហចៅក្រមស៊ើបអង្កេត បទដ្ឋាននៃភស្តុតាង ដើម្បីចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ និង យុត្តាធិការបុគ្គល។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ គឺជាព័ត៌មានដែលទើបតែរកឃើញថ្មីៗ ដែលមេធាវីការពារក្តីត្រូវតែការពារក្តីដោយយកចិត្តទុកដាក់ឱ្យបានត្រឹមត្រូវ ក្នុងការការពារសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ លោក មាស មុត។ ដើម្បីធានាថា សហចៅក្រមស៊ើបអង្កេតវាយតម្លៃលើភស្តុតាងនៅក្នុងរឿងក្តី ០០៣ ដូចដែលបានធ្វើនៅក្នុងរឿងក្តី ០០៤/១ អនុវត្តបទដ្ឋាននៃភស្តុតាងត្រឹមត្រូវដើម្បីចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ និង វាយតម្លៃយ៉ាងត្រឹមត្រូវលើយុត្តាធិការបុគ្គល មេធាវីការពារក្តីគួរត្រូវបានអនុញ្ញាត ឱ្យដាក់សារណាបន្ថែមលើចម្លើយរបស់ខ្លួន តបទៅនឹងដីកាសន្និដ្ឋានស្ថាពរ។

**អាស្រ័យហេតុនេះ** ដូចបានបង្ហាញជូនក្នុងសំអាងហេតុខាងលើ មេធាវីការពារក្តីគោរពស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតមេត្តា**អនុញ្ញាត** ឱ្យមេធាវីការពារក្តីដាក់សារណាបន្ថែម លើចម្លើយរបស់ មាស មុត តបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ។

---

បានប្រព្រឹត្ត...”។ ២ ថ្មី៖ “ត្រូវបានបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់ ... **ដើម្បីជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ** និង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត...” (ការគូសបញ្ជាក់បន្ថែម)។

[85] វិធានផ្ទៃក្នុង ៥៥(៤) វិធាន ៦៧(៣) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ ដូចខាងលើ* សទ្ទានុក្រម និយមន័យនៃពាក្យជនសង្ស័យ និង ជនត្រូវចោទ។

[86] *សូមមើល* វិធានផ្ទៃក្នុង ៥៥(៤) ទាក់ទងនឹងបទចោទប្រកាន់ជនសង្ស័យ។

[87] មាត្រា ១៣(១) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក.។ មាត្រា ៣៥ថ្មី (ក) (ឃ) នៃច្បាប់ស្តីពីបង្កើត អ.វ.ត.ក.។ វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង។

សូមសហចៅក្រមស៊ើបអង្កេតមេត្តាទទួលយកសំណើនេះដោយគោរព។

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី **៦ ខែសីហា** ឆ្នាំ **២០១៨**

សហមេធាវីការពារក្ដីលោក មាស មុត

អាង ឧត្តម

Michael G. KARNAVAS